ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៤ លេខ ៣៦ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

មាតិកា

I ខុទ្ទកាល័យព្រះមហាក្សត្រ

១—ព្រះរាជក្រឹត្យ

១៨.៩.៩៦ ព្រះរាជក្រឹត្យ នស/រកត/០៩៩៦/៧៣ តែងតាំងឯកឧត្តម ច័ន្ទ តានី ជាទីប្រឹក្សាផ្ទាល់របស់ឯកឧត្តម ឡូយ ស៊ីមឈាង អនុប្រធានទី ១ នៃរដ្ឋសភា ១៥៧៩

II ទីស្តីការគណៈរដ្ឋមន្ត្រី

១—អនុក្រឹត្យ

២៥.៩.៩៦ អនុក្រឹត្យលេខ ៤០ អនក្រ.បក ស្តីពីការកំណត់លក្ខណៈវិនិច្ឆ័យមន្ត្រីរាជការស៊ីវិល ដែលស្នើសុំពន្យារពេលចូលនិវត្តន៍ ១៥៨០

៣០.៩.៩៦ អនុក្រឹត្យលេខ ១៨២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៥៨២

៣០.៩.៩៦ អនុក្រឹត្យលេខ ១៨៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៥៨៥

៣០.៩.៩៦ អនុក្រឹត្យលេខ ១៨៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៥៨៦

៣០.៩.៩៦ អនុក្រឹត្យលេខ ១៨៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៥៨៧

៣០.៩.៩៦ អនុក្រឹត្យលេខ ១៨៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៥៨៨

៣០.៩.៩៦ អនុក្រឹត្យលេខ ១៨៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៥៨៩

៣០.៩.៩៦ អនុក្រឹត្យលេខ ១៨៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៥៩០

៣០.៩.៩៦ អនុក្រឹត្យលេខ ១៨៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៥៩១

៣០.៩.៩៦ អនុក្រឹត្យលេខ ១៩០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៥៩៣

៣០.៩.៩៦ អនុក្រឹត្យលេខ ១៩១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៥៩៤

២— សេចក្តីសំរេច

២៦.៩.៩៦ សេចក្តីសំរេចលេខ ៤០ សសរ យល់ព្រមអោយធ្វើសមាហរ័ណកម្ម កំលាំង ដោយបញ្ចូលកំលាំងកងទ័ពទាំងអស់គ្រប់កងឯកភាព របស់ក្រុមផ្តាច់ខ្លួន ចូលមកក្នុងកំលាំងរបស់កងយោធពលខេមរ ភូមិន្ទ ១៥៩៦
៣០.៩.៩៦ សេចក្តីសំរេចលេខ ៤១ សសរ ស្តីពីការផ្ទេរសិទ្ធិ ១៥៩៩

III ការងារបណ្តាក្រសួង

ប្រកាសអន្តរក្រសួង

១—ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងយុត្តិធម៌

២៥.៩.៩៦ ប្រកាសលេខ ៤៨៧ សហវ.មប្រក ស្តីពីការតែងតាំងរដ្ឋទេយ្យករ បុរេប្រទាន នៅក្រសួងយុត្តិធម៌ ១៦០០
២៥.៩.៩៦ ប្រកាសលេខ ៤៨៨ សហវ.មប្រក ស្តីពីការបង្កើតរដ្ឋទេយ្យបុរេ ប្រទាន នៅក្រសួងយុត្តិធម៌ ១៦០២
២៥.៩.៩៦ ប្រកាសលេខ ៤៨៩ សហវ.មប្រក ស្តីពីការបង្កើត និង តែងតាំង ភ្នាក់ងារបើកផ្តល់ សំរាប់បើកបៀវត្សជូនមន្ត្រីរាជការ

២—ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងបរិស្ថាន

២៧.៩.៩៦ ប្រកាសលេខ ៥០៥ សហវ.មប្រក ស្តីពីការតែងតាំងរដ្ឋទេយ្យករ បុរេប្រទាននៅក្រសួងបរិស្ថាន ១៦០៦
២៧.៩.៩៦ ប្រកាសលេខ ៥០៦ សហវ.មប្រក ស្តីពីការបង្កើតនិងតែងតាំង ភ្នាក់ងារបើក ផ្តល់សំរាប់បើកបៀវត្សជូនមន្ត្រីរាជការ ១៦០៨
២៧.៩.៩៦ ប្រកាសលេខ ៥០៧ សហវ.មប្រក ស្តីពីការបង្កើតរដ្ឋទេយ្យចំណូល នៅក្រសួងបរិស្ថាន ១៦១០

២៧.៩.៩៦ ប្រកាសលេខ ៥០៨ សហវ.មប្រក ស្ដីពីការតែងតាំងរដ្ឋទេយ្យ ចំណូលនៅក្រសួងបរិដ្ឋាន ១៦១២

២៧.៩.៩៦ ប្រកាសលេខ ៥០៩ សហវ.មប្រក ស្ដីពីការបង្កើតរដ្ឋទេយ្យករ បុរេប្រទាននៅក្រសួងបរិដ្ឋាន ១៦១៣

៣—ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងពត៌មាន

៣០.៩.៩៦ ប្រកាសលេខ ៥១១ សហវមប្រក ស្ដីពីការតែងតាំងរដ្ឋទេយ្យករបុរេ នៅក្រសួងពតិមាន ១៦១៥

៣០.៩.៩៦ ប្រកាសលេខ ៥១២ សហវ.មប្រក ស្ដីពីការតែងតាំងរដ្ឋទេយ្យករ បុរេនៅក្រសួងពតិមាន ១៦១៧

៣០.៩.៩៦ ប្រកាសលេខ ៥១៣ សហវ.មប្រក ស្ដីពីការបង្កើតរដ្ឋទេយ្យ ចំណូលនៅក្រសួងពតិមាន ១៦១៩

៣០.៩.៩៦ ប្រកាសលេខ ៥១៤ សហវ.មប្រក ស្ដីពីការបង្កើត និង តែងតាំង ភ្នាក់ងារបើកផ្ដល់ សំរាប់បើកបៀវត្សជូនមន្ត្រីជរាការ ១៦២១

៣០.៩.៩៦ ប្រកាសលេខ ៥១៦ សហវ.មប្រក ស្ដីពីការតែងតាំងរដ្ឋទេយ្យ ចំណូលនៅក្រសួងពតិមាន ១៦២៣

៤—ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

ប្រកាស

៣០.៩.៩៦ ប្រកាសលេខ ៥៧៥ ផក.ប្រក អនុញ្ញាតអោយលោក **ហឿង ឌីន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ជាប្រធានរោងម៉ាស៊ីនកិនស្រូវផ្ទេរភារកិច្ចគ្រប់គ្រងជូនលោក **សេង ឈុនឡាយ** វិញ ១៦២៥

៣០.៩.៩៦	ប្រកាសលេខ ៥៧៦ ផក.ប្រក អនុញ្ញាតអោយលោក **គួ សុខគី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១២០ សេះ	១៦២៥
៣០.៩.៩៦	ប្រកាសលេខ ៥៧៧ ផក.ប្រក អនុញ្ញាតអោយលោក **ហង់ សុខា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការសាខាទី ១ រោងម៉ាស៊ីនកិនស្រូវ ៨០ កំលាំង	១៦២៦

៥—ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

៣០.៩.៩៦	ប្រកាសលេខ ៣០៥ ពណ.បល.ប្រក បង្កើតមជ្ឈមណ្ឌលតំកល់ឯកសារ	១៦២៧

៦—រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្តីសំរេច

៣០.៩.៩៦	សេចក្តីសំរេចលេខ ៥៤៨ សសរ.មស.ក្រខ ស្តីពីការបែងចែកសិស្សនិស្សិតចំនួន ៥៣ នាក់ ដែលទើបបញ្ចប់ការសិក្សាពីក្រៅប្រទេស	១៦២៨

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស.រកត.០៩៩៦.៧៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្តីសំរេចរបស់រដ្ឋសភា ស្តីពីការជ្រើសតាំងសម្តេច **ជា ស៊ីម** ជាប្រធាន រដ្ឋសភា ឯកឧត្តម **ឡូយ ស៊ីមឈាង** ជាអនុប្រធានទី ១ នៃរដ្ឋសភា នាសម័យប្រជុំពេញអង្គ លើកទី ១ នីតិកាលទី ១ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៣
- យោងតាមសំណើរបស់ប្រធានរដ្ឋសភាស្តីទី ចុះថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ចំន្ទ តានី** ជាទីប្រឹក្សាផ្ទាល់របស់ឯកឧត្តម **ឡូយ ស៊ីមឈាង** អនុប្រធានទី ១ នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើរដ្ឋលេខាធិការ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងអគ្គលេខាធិការរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៦

ព្រះហស្ថលេខា

នរោត្តម សីហនុ

* * *

II - ទីស្តីការគណៈរដ្ឋមន្ត្រី

១—អនុក្រឹត្យ

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៤០ អនក្រ.បក

ស្តីពីការកំណត់លក្ខណៈវិនិច្ឆ័យ

មន្ត្រីរាជការស៊ីវិល ដែលស្នើសុំពន្យារពេលចូលនិវត្តន៍

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ដែលប្រកាសអោយប្រើ ដោយព្រះរាជ ក្រមលេខ ០៦ នស.៩៤ ចុះថ្ងៃទី ៣០ តុលា ឆ្នាំ ១៩៩៥
- យោងតាមសភាពការណ៍ចាំបាច់

សំរេច

មាត្រា ១ : មន្ត្រីរាជការទាំងពីរភេទ ដែលដល់អាយុ ៥៥ឆ្នាំ ត្រូវដាក់អោយចូលនិវត្តន៍ លើក លែងតែករណីដូចមានចែងក្នុងមាត្រា ២ ខាងក្រោម ÷

មាត្រា ២ : ចាប់ពីពេលនេះរហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ១៩៩៩ រាជរដ្ឋាភិបាលអាចអនុញ្ញាត អោយ អ្នករាជការដែលមានអាយុលើសពី ៥៥ឆ្នាំ បន្តធ្វើការងារ ដើម្បីឆ្លើយតបនឹង សេចក្តីត្រូវការនូវអ្នកមានសមត្ថភាពខ្ពស់ និងមានបទពិសោធន៍ ។ ការអនុញ្ញាត ពិសេសនេះត្រូវសំរេចដោយអនុក្រឹត្យ ។

មាត្រា ៣ : មន្ត្រីរាជការស៊ីវិលដែលអាចសុំពន្យារពេលចូលនិវត្តន៍បាន ត្រូវមានលក្ខណៈ វិនិច្ឆ័យដូចខាងក្រោម ÷

- មន្ត្រីដែលមានកិរិតជំនាញបច្ចេកទេស ដែលក្រសួងស្ថាប័នត្រូវការជាចាំបាច់ ហើយពុំទាន់មានអ្នកជំនួស នៅឡើយ ។
- ត្រូវមានកាយសម្បទាគ្រប់គ្រាន់ អាចធានាបំរើការងារបន្តបាន ។
- មានស្មារតីខិតខំប្រឹងប្រែងបំពេញការងារ មានស្នាដៃល្អ ។
- មានកិរិយាមាយាទល្អ និង ស្អាតស្អំ ។
- មានសតិសម្បជញ្ញៈទទួលខុសត្រូវក្នុងកិច្ចការដែលបានទទួលបន្ទុក ។
- មានទំនាក់ទំនងល្អជាមួយសហសេវិក និងជាមួយមហាជន ។

មាត្រា ៤ : ការស្នើសុំពន្យារពេលចូលនិវត្តន៍ ត្រូវមានសំណុំលិខិតដូចខាងក្រោម ÷

- លិខិតស្នើសុំពន្យារពេលចូលនិវត្តន៍របស់សាមីជន និងការវាយតម្លៃរបស់ ប្រធានស្ថាប័នសាមីភ្ជាប់ជាមួយ។
- ជីវប្រវត្តិសង្ខេបរបស់សាមីជន ដោយមានបិទរូបថត និងមានការបញ្ជាក់ពី ស្ថាប័នសាមី ។
- របាយការណ៍ផ្ទាល់ខ្លួន អំពីលក្ខណៈសម្បត្តិ ដូចមានចែងក្នុងមាត្រា ៣ ខាង លើ ព្រមទាំងមានការបញ្ជាក់ត្រឹមត្រូវពីស្ថាប័នសាមី ។

មាត្រា ៥ : ក្រសួងស្ថាប័ននីមួយៗ ត្រូវលើកសំណើពន្យារពេលចូលនិវត្តន៍នៃមន្ត្រីរាជការមករដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ចំនួន ០១លើកក្នុង ០១ ឆ្នាំ គឺយ៉ាងយូរបំផុតត្រឹមថ្ងៃទី ៣១ ខែ ឧសភា នៃឆ្នាំនីមួយៗ នូវមន្ត្រីរាជការដែលស្នើសុំពន្យារពេលចូលនិវត្តន៍នៃឆ្នាំបន្ទាប់ ដែលរដ្ឋលេខាធិការដ្ឋានមុខងារ សាធារណៈត្រូវធ្វើការបូកសរុប និងដាក់ជូនគណៈកម្មការពិនិត្យការសុំពន្យារពេលចូលនិវត្តន៍របស់មន្ត្រីរាជការស៊ីវិល ។

គណៈកម្មការពិនិត្យការសុំពន្យារពេលចូលនិវត្តន៍របស់មន្ត្រីរាជការស៊ីវិលពិនិត្យនិងលើកសំណើតាមនីតិវិធី ដើម្បីសុំការសំរេចតាមរយៈអនុក្រឹត្យ ។

មាត្រា ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៨២ អនក្រ.តត
ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ

១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– បានឃើញ ព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

– តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ ស្ថាបនាជាតិ តាមលំដាប់ថ្នាក់ជូនសប្បុរសជនចំនួន ២៧ រូបដែលបានបរិច្ចាគធនធានចូលរួមជួយកសាងសមិទ្ធផលផ្សេងៗ ជាប្រយោជន៍សាធារណៈជូនប្រជាពលរដ្ឋក្នុងខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម ៖

ក–មេដាយមាស ស្ថាបនាជាតិ

១–លោក **ឆោ ឡូ**	និងភរិយា	បរិច្ចាគប្រាក់	២៥.០០០$US
២–ឯកឧត្តម **គន់ គីម**		បរិច្ចាគប្រាក់	៥១.៣២០.០០០រៀល
៣–លោក **ណា ម៉ារ៉ាឌី**	និងភរិយា	បរិច្ចាគប្រាក់	៥២.០០០.០០០ រៀល
៤–លោក **ស៊ុម វណ្ណា**	និងភរិយា	បរិច្ចាគប្រាក់	១៥.៩៤៨ $ US
៥–លោក **សៀក ពិសិដ្ឋ**	និងភរិយា	បរិច្ចាគប្រាក់	១៤.៧០០ $ US
៦–លោក **ម៉ក់ គីមហុង**	និងភរិយា	បរិច្ចាគប្រាក់	១៣.៣០៧ $ US

ខ–មេដាយប្រាក់ ស្ថាបនាជាតិ

១–ឯកឧត្តម **ខៀវ កាញារីទ្ធ**	បរិច្ចាគប្រាក់	១៣.០០០.០០០រៀល
២–លោក ជំទាវ **សួ ស្រ៊ុន**	បរិច្ចាគប្រាក់	៧.០០០,១០០ $ US
៣–លោក **ឡោក សុគជា**	បរិច្ចាគប្រាក់	៧.៥០០$US
៤–លោក **ស សាម៉ុន**	បរិច្ចាគប្រាក់	៦.០០០$US
៥–លោក **ឡាន់ ឆន**	បរិច្ចាគប្រាក់	២០.៧៨០.០០០ រៀល
៦–លោក **ឡុង ឆាម**	បរិច្ចាគប្រាក់	១៨.៤៩០.០០០ រៀល

គ–មេដាយសេរីវឌ្ឍ ស្ថាបនាជាតិ

១–សម្តេចមង្គលទេពាចារ្យ អ៊ុំ ស៊ុំ	បរិច្ចាគប្រាក់	២.៤០០ $ US
២–ឯកឧត្តម ពូ សុធីរៈ	បរិច្ចាគប្រាក់	៣.៧០០ $ US
៣–ឯកឧត្តម ហូ សុខ	បរិច្ចាគប្រាក់	៣.៣២០ $ US
៤– ឯកឧត្តម អ៊ុក ប៊ុនឈឿន	បរិច្ចាគប្រាក់	២.០០០ $ US
៥–លោក គីម ជ័រ	បរិច្ចាគប្រាក់	១.៥០០ $ US
៦–លោក សាយ គីមហេង	បរិច្ចាគប្រាក់	៤.០០០.០០០ រៀល
៧–លោក ពុត ផន	បរិច្ចាគប្រាក់	១.៧៨០ $US
៨–លោក ឆូ ធីណារ៉ា	បរិច្ចាគប្រាក់	២.០០០ $US
៩–លោក នាង ណារ៉ាត	បរិច្ចាគប្រាក់	២.២៥០ $US
១០–លោក គួង ស៊ីផាន	បរិច្ចាគប្រាក់	១២.០០០.០០០ រៀល
១១–លោក អេង ឈុន	បរិច្ចាគប្រាក់	៥.០០០.០០០ រៀល
១២–លោក ឡាយ សុខា	បរិច្ចាគប្រាក់	៧.០០០.០០០ រៀល
១៣–លោក ស្លូវ ណារ៉ាត	បរិច្ចាគប្រាក់	១.០៦០ $US
១៤–លោក ឡុច ឆៃ	បរិច្ចាគប្រាក់	១.១០០ $US
១៥–លោក សុក ហេង	បរិច្ចាគប្រាក់	៥.៤៦៥.០០០ រៀល

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្ត កំពង់ចាម ត្រូវអនុវត្តតាមអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៨៣ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ មាស ស្ថាបនាជាតិជូនសប្បុរសជន ០២ រូប ដែលមានសទ្ធាជ្រះថ្លាៈបានបរិច្ចាគធនផ្ទាល់ខ្លួន សំរាប់រួមចំណែកកសាងសមិទ្ធផលផ្សេងៗជូនជាតិ និង ជួយដោះស្រាយ ទុក្ខលំបាករបស់ប្រជារាស្ត្រនៅជនបទ ដូចមានខាងក្រោមនេះ ÷

១-លោក **ង៉ោ ឡូ** ប្រធានក្រុមហ៊ុនចំការកៅស៊ូចំការអណ្តូង បរិច្ចាគទឹកប្រាក់ ១២៧.៥០០$US

២-លោក **ស៊ុម វណ្ណា** ប្រធានក្រុមហ៊ុនចំការកៅស៊ូបឹងកេត បរិច្ចាគទឹកប្រាក់ ១១០.១៤៨ $US

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៦

អនុក្រឹត្យ ១៨៤ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាស អោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តពោធិសាត់

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ មាស ស្ថាបនាជាតិ ជូនអង្គការ CARERE ប្រចាំខេត្តពោធិសាត់ ដែលបានផ្តល់អំណោយអាគារមួយខ្នងដោយមានបំពាក់សំភារៈបរិក្ខារគ្រប់គ្រាន់ជូនមជ្ឈមណ្ឌលកិច្ចការនារីខេត្តពោធិសាត់ សំរាប់មណ្ឌុះបណ្តាល

វិជ្ជាជីវៈនារី ដែលមានតម្លៃជាទឹកប្រាក់ ៣៨.០០០ ដុល្លារសហរដ្ឋអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាល ខេត្តពោធិសាត់ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៨៥ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិជូនសប្បុរសជន ០៣ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន សំរាប់ចូលរួមកសាងសមិទ្ធផលផ្សេងៗនៅក្នុងខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោមនេះ ÷

ក—មេដាយមាសស្ថាបនាជាតិ

១—លោក ឆោរ ឌី កសាងអាគារសិក្សា ០២ ខ្នងអស់ទឹកប្រាក់ ៤០.០០០ $ US

ខ—មេដាយប្រាក់ស្ថាបនាជាតិ

១—ឯកឧត្តម ចៅ ម៉េងលាត ជួសជុលផ្លូវលំមួយខ្សែអស់ទឹកប្រាក់ ៥.០០០ $ US

២—លោកជំទាវ លាង ទួចឆេង កសាងអាគារសិក្សាមួយខ្នងអស់ទឹកប្រាក់ ៥.០០០$US

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាមត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឬទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៨៦ អនក្រ.តត
ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តស្វាយរៀង

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ ប្រាក់ ស្ថាបនាជាតិ ជូនអង្គការ «មូលនិធិ ខុនរ៉ាដ-អាដិនណៅ អ៊ែរ » ប្រទេសអាល្លឺម៉ង់ ដែលបានផ្តល់ថវិកាចំនួន ៨.៣៦៧,៣២$ US សំរាប់កសាងវត្តបប្ជាន នៅឃុំចាទី ស្រុក ចន្ទ្រា ខេត្តស្វាយរៀង ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៨៧ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រីទី ២

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិ ជូនលោក **អ៊ីខ ម៊ិនហ៊្វេង** នាយកក្រុមហ៊ុន AZDISTRIBUTION CO Ltd ដែលបានបរិច្ចាគថវិកាចំនួន ២៥.៥០០$ US សំរាប់ជួយសាងសង់អាគារសិក្សាមួយខ្នង នៅវិទ្យាល័យ **ហ៊ុន សែន** តាខ្មៅ និងជីកស្រះទឹក ជូនប្រជាពលរដ្ឋ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាល ខេត្តកណ្តាល ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។'

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៨៨ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើររបស់អភិបាលខេត្តកណ្តាល

សម្រេច

មាត្រា ១ :ត្រូវបានប្រគល់មេដាយ មាស ស្ថាបនាជាតិ ជូនសមាគមបារាំង AUPEF UREF ដែល បានជួយសាងសង់អាគារសិក្សាមួយខ្នង នៅសាលាបឋមសិក្សា ព្រែកឫស្សី ឃុំព្រែកឫស្សី ស្រុកតាខ្មៅ ខេត្តកណ្តាល ចំណាយអស់ទឹកប្រាក់ ១០.៧០០$ US ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាល ខេត្តកណ្តាល ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបាលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៨៩ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ មាស ស្ថាបនាជាតិ ជូនសប្បុរសជន ០២ រូប ដែលបានបរិច្ចាគធនធាន ជួយកសាងអាគារសិក្សា ០២ ខ្នង ដោយមានបំពាក់សំភារៈគ្រប់គ្រាន់នៅសាលា បឋមសិក្សា បដិមាករ ក្នុងឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល ដូចមាននាមខាងក្រោម :

១-លោក **ហ្គូតូ ហ្វូមីអូ** ជនជាតិជប៉ុន បរិច្ចាគប្រាក់ ១៨.៨០០$US

២-លោក **មាស ម៊ុនវ៉ា** អាណិកជនខ្មែរនៅប្រទេសជប៉ុន បរិច្ចាគប្រាក់ ១៨.០០០$US

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាល ខេត្តកណ្តាល ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៩០ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៦ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិជូនសប្បុរសជន ០២ រូប ដែលបានបរិច្ចាគ ថវិកាចូលរួមជួយកសាងសមិទ្ធផលផ្សេងៗជូនជាតិ ដូចមាននាមខាងក្រោមនេះ ។

១–HE Mr SHOHEI NAITO ទឹកប្រាក់ចំនួន ៧០.២០៩ $US កសាងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ **ហ៊ុន រ៉ានី ហ៊ុន សែន** អង្គស្នួល ។

២–លោក **ម៉ុន ហ៊ួច** ទឹកប្រាក់ ចំនួន ៤៦.៥០០$US កសាងអាគារសិក្សា ០២ ខ្នង និង ស្រះទឹកមួយ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាល ខេត្តកណ្តាល ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៩១ អនក្រ.តត

ស្តីពីការជូនមេដាយ ស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាស អោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិជូនសប្បុរសជនចំនួន ២០ រូប ដែលបាន បរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលផ្សេងៗ ជាប្រយោជន៍សាធារណៈជូន ប្រជាពលរដ្ឋនៅខេត្តកំពង់ចាមនាដើមឆ្នាំ ១៩៩៦ នេះ ដូចមានរាយ

នាមខាងក្រោម ÷

១–ឯកឧត្តម **ឯម សំអាន**	បរិច្ចាគទឹកប្រាក់	៣២.៤០០ $ US
២–ឯកឧត្តម **ឌា ចរ៉ាត់**	បរិច្ចាគទឹកប្រាក់	៣១.៣០០$ US
៣–ឯកឧត្តម **សាយ ឈុំ**	បរិច្ចាគទឹកប្រាក់	១៨.៧៦០$ US
៤–លោក **ទី លន់**	បរិច្ចាគទឹកប្រាក់	៤២.៥០០ $ US
៥–លោក **ឈិត គឹមយ៉ាន**	បរិច្ចាគទឹកប្រាក់	៧៥.៥០០ $ US
៦–លោក **ជា អ៊ាងលិម**	បរិច្ចាគទឹកប្រាក់	១៦.៥០០ $ US
៧–លោក **ឡូច សែតេង**	បរិច្ចាគទឹកប្រាក់	១៦.៥០០ $ US
៨–លោក **ខៀវ ផន**	បរិច្ចាគទឹកប្រាក់	១១.៧៥០ $ US
៩–លោក **ហែម ឡាយ**	បរិច្ចាគទឹកប្រាក់	៥៧. ជម្លឹងមាស
១០–លោក **តា ចុន**	បរិច្ចាគទឹកប្រាក់	២០.០០០ $ US
១១–លោក **ចក់ ឡេង**	បរិច្ចាគទឹកប្រាក់	១៣.០០០ $ US
១២–លោក **សារីភាព** (ប្រាក់)	បរិច្ចាគទឹកប្រាក់	១៥.០០០ $ US
១៣–ឧបាសក **សាត នៅ**	បរិច្ចាគទឹកប្រាក់	៩៧.០០០.០០០ រៀល
១៤–ព្រះភិក្ខុ **សុវណ្ណ**	បរិច្ចាទឹកប្រាក់	៧៤.០០០.០០០ រៀល
១៥–លោក **ឆុច ថាត**	បរិច្ចាគទឹកប្រាក់	២០.០០០ $ US
១៦–លោក **ស៊ុម វណ្ណា**	បរិច្ចាគទឹកប្រាក់	១៥.០០០ $ US
១៧–លោក **ឈា ម៉ារ៉ាឌី**	បរិច្ចាគទឹកប្រាក់	៣៥.០១៣.៨០០ រៀល
១៨–លោក **ម៉ក់ គឹមហុង**	បរិច្ចាគទឹកប្រាក់	៥៨.៥០១.៨០០ រៀល
១៩–លោក **ឆោ ទ្វី**	បរីច្ចាគទឹកប្រាក់	២០.០០០ $ US
២០–លោក **ឆោ ឌី**	បរិច្ចាគទឹកប្រាក់	៤៦.០០០ $ US

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្ត កំពង់ចាម ត្រូវអនុវត្តតាមអនុក្រឹត្យ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

២– សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ១៩៨៦

សេចក្តីសំរេចលេខ ៤០ សសរ.

យល់ព្រមអោយធ្វើសមាហរណកម្មកំលាំង
ដោយបញ្ចូលកំលាំងកងទ័ពទាំងអស់គ្រប់កង
ឯកភាពរបស់ក្រុមផ្តាច់ខ្លួន ចូលមកក្នុងកំលាំង
របស់កងយោធពលខេមរភូមិន្ទ

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
– បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
– យោងតាមមាត្រាទី ៣ជំពូក ១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ដែលបានចែងថា "ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋដែលមិនអាចបំបែកបាន" ។
– យោងតាមសភាពការណ៍វិវត្តន៍នៃកំលាំងពួកឧទ្ទាមខ្មែរក្រហម ដែលកំពុងមានទំនាស់បែកបាក់ផ្ទៃក្នុង និង កើតមានឡើងនូវក្រុមផ្តាច់ខ្លួន ។
– យោងតាមសេចក្តីសំរេចលេខ ៣៤ សសរ. ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៦ ស្តីពីកាបេង្កើតគណៈកម្មាធិការសំរាប់សំរួលដោះស្រាយជួយឧបត្ថម្ភដល់បងប្អូនមករួមរស់ក្នុងសង្គមជាតិ ទិសពាយព្យ ។

- យោងតាមស្មារតី នៃការជួបប្រជុំពិភាក្សារវាងឯកឧត្តមសហរដ្ឋមន្ត្រីក្រសួងការពារជាតិជាមួយឯកឧត្តម អៀង សារី កាលពីថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ១៩៩៦ នាទីក្រុងបាងកក ។
- យោងតាមព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៦/៧២ ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៦ ស្តីពីការលើកលែងទោសអោយឯកឧត្តម អៀង សារី អតីតឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការបរទេសក្នុងរដ្ឋាភិបាល នៃប្រទេសកម្ពុជាប្រជាធិបតេយ្យ ។
- យោងតាមស្មារតីនៃការជួបប្រជុំរវាងគណៈកម្មាធិការសំរាប់សំរួលដោះស្រាយឧបត្ថម្ភដល់បង ប្អូនមករួមរស់ក្នុងសង្គមជាតិទិសពាយព្យ ជាមួយតំណាងនៃក្រុមផ្តាច់ខ្លួនចេញពីពួកឧទ្ទាម កាលពីថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៩៦ នៅតំបន់ប៉ៃលិន ។
- យោងតាមស្មារតីប្រជុំអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : ត្រូវបានយល់ព្រមអោយធ្វើសមាហរណកម្មកម្លាំងដោយបញ្ចូលកម្លាំងកងទ័ពទាំងអស់គ្រប់កង ឯកភាពរបស់ក្រុមផ្តាច់ខ្លួន ចូលមកក្នុងកំលាំងរបស់កង យោធពលខេមរភូមិន្ទ ។

ការធ្វើសមាហរណកម្មកម្លាំងនេះ ត្រូវប្រព្រឹត្តនៅក្រោមការរៀបចំ និងផែនការរបស់អគ្គសេនាធិការកងយោធពលខេមរភូមិន្ទ ។

សហរដ្ឋមន្ត្រីក្រសួងការពារជាតិជាអ្នកពិនិត្យសំរេច និងលើកសំណើ ស្តីពីការតែងតាំងមុខតំណែង និងឋានន្តរសក្តិអោយនាយទាហានទាំងឡាយនៃកងទ័ពរបស់ក្រុមផ្តាច់ខ្លួននេះ ។ កំលាំងកងទ័ពទាំងអស់នៃក្រុមផ្តាច់ខ្លួនដែលត្រូវបានធ្វើសមាហរណកម្មកម្លាំង នេះត្រូវប្តូរ ឯកសណ្ឋានមកស្លៀកពាក់ឯកសណ្ឋានកងយោធពលខេមរភូមិន្ទ
នៅពេលប្រកាស ។

ប្រការ ២ : មុនពេលមានព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុង ឬ ខេត្តប៉ៃលិន ឬ បង្កើតស្រុកថ្មីបន្ថែម អាជ្ញាធរដែនដីតាមព្រំប្រទល់រដ្ឋបាលបច្ចុប្បន្នត្រូវរៀបចំការគ្រប់គ្រង

រដ្ឋបាល និងប្រជាជនតាមសមត្ថកិច្ចរៀងៗខ្លួន និងតាមសភាពជាក់ស្តែងដោយមានការសហការពីបងប្អូនផ្តាច់ខ្លួន ។

ប្រការ ៣ : គណៈកម្មាធិការសំរាប់សំរួលដោះស្រាយជួយឧបត្ថម្ភដល់បងប្អូនមករួមរស់ក្នុងសង្គមជាតិ ទិស ពាយ័ព្យ ដែលបង្កើតដោយសេចក្តីសំរេចថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៨៦ ដែលមានសហការពីស្ថាប័នពាក់ព័ន្ធត្រូវ ÷

- ធ្វើស្ថិតិចំនួននាយទាហាន ពលទាហាន សំភារៈមធ្យោបាយ យុទ្ធោបករណ៍ ដើម្បីបញ្ចូលក្នុងការគ្រប់គ្រង របស់អគ្គសេនាធិការ និងក្រសួងការពារជាតិ ។
- ចុះបញ្ជីចលនទ្រព្យ និងអចលនទ្រព្យ ដែលជាសម្បត្តិរដ្ឋបញ្ជូនអោយស្ថាប័នពាក់ព័ន្ធ ។
- ធ្វើស្ថិតិប្រជាពលរដ្ឋតាមតំបន់បញ្ជូនអោយអាជ្ញាធរដែនដីក្នុងតំបន់រដ្ឋបាលខេត្តស្រុកដែលគ្រប់គ្រងតំបន់ នោះ ។
- ធ្វើស្ថិតិប្រជាពលរដ្ឋ និងធ្វើទំនាក់ទំនងជាមួយអាជ្ញាធរខេត្ត ក្រុងទូទាំងប្រទេស ព្រមទាំងជួយសំរួលដល់ ប្រជាពលរដ្ឋក្នុងតំបន់ទាំងនេះ ដែលស្ម័គ្រចិត្តទៅរួមរស់ជាមួយគ្រួសារឯភូមិកំណើត ។
- លើកគំរោងថវិកាដែលត្រូវចំណាយសំរាប់បៀវត្សទាំងយោធា និងស៊ីវិល ព្រមទាំងការចំណាយផ្សេងៗទៀត ជូនគណៈរដ្ឋមន្ត្រីពិនិត្យសំរេច ដើម្បីបញ្ចូលក្នុងថវិកាជាតិ ។
- រួមជាមួយស្ថាប័នពាក់ព័ន្ធ ដោះស្រាយបញ្ហាជាក់ស្តែងចំពោះមុខ ដូចជាការបើកផ្លូវតភ្ជាប់ បំផ្លាញចោលមីន ទំនាក់ទំនងជាមួយអង្គការមនុស្សធម៌ និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីជួយឧបត្ថម្ភដល់ប្រជាពលរដ្ឋ ដែលជួបការលំបាក ។

ប្រការ ៤ : អនុគណៈកម្មាធិការតាមទិស យោធភូមិភាគនីមួយៗ ត្រូវរួមជាមួយស្ថាប័នពាក់ព័ន្ធក្រោមការដឹកនាំរបស់គណៈកម្មាធិការសំរាប់សំរួលដោះស្រាយឧបត្ថម្ភដល់បងប្អូនមករួមរស់ក្នុងសង្គមជាតិទិសពាយ័ព្យ ត្រូវធ្វើការបញ្ចូលកំលាំងទាំងយោធា និងស៊ីវិលតាមតំបន់រៀងៗខ្លួនដោយមិនរង់ចាំការបញ្ចូលទាំងស្រុងនូវ កំលាំងផ្តាច់ខ្លួនទាំងអស់ ។

ប្រការ ៥ : គណៈកម្មការទំនាក់ទំនងព្រំដែនកម្ពុជា_ថៃ ត្រូវដំណើរការសហការជាមួយភាគីថៃ ដើម្បីគ្រប់គ្រងតំបន់ព្រំដែននៃប្រទេសទាំងពីរ អោយបានល្អធានាសន្តិសុខ សណ្តាប់ធ្នាប់ និងសហប្រតិបត្តិការល្អ ។

ប្រការ ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ គណៈកម្មាធិការសំរាប់សំរួលដោះស្រាយឧបត្ថម្ភ ដល់បងប្អូនមករួមរស់ក្នុងសង្គមជាតិនៅទិសពាយ័ព្យ បងប្អូននាយទាហានពល ទាហានគ្រប់កងឯកភាព ព្រមទាំងកំលាំងទាំងអស់នៃក្រុមផ្តាច់ខ្លួន និងស្ថាប័ន ពាក់ព័ន្ធមានភារកិច្ចអនុវត្ត តាមសេចក្តីសំរេចនេះដោយត្រឹមត្រូវ និងមានប្រសិទ្ធ ភាពខ្ពស់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

_ការប្រព្រឹត្តផ្ទុយពីនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៧ : សេចក្តីសំរេចណាដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ៤១ សសរ.

ស្តីពីការផ្ទេរសិទ្ធិ

* * *

រាជរដ្ឋាភិបាលកម្ពុជា

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សំរេច

ប្រការ ១ : ផ្ទេរសិទ្ធិជូនឯកឧត្តម **ជា ចាន់តូ** រដ្ឋមន្ត្រីក្រសួង ផែនការ ជារដ្ឋមន្ត្រីស្តីទី នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជំនួសឯកឧត្តម **គាត ឈន់** ដែលត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅបរទេស ចាប់ពីថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ១៩៩៦ រហូតដល់ឯកឧត្តមបញ្ចប់បេសកកម្ម ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និងឯកឧត្តម **ជា ចាន់តូ** ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

III - ការងារបណ្តាក្រសួង

ប្រកាសអន្តរក្រសួង

១- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងយុត្តិធម៌

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសអន្តរក្រសួងលេខ ៤៨៧ សហវ.មប្រក.

ស្តីពីការតែងតាំងរដ្ឋលេខាធិការប្រចាំស្ថាន

នៅក្រសួងយុត្តិធម៌

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុ ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ១១ នស.៩៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញត្តទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ អនុវត្តបទបញ្ញត្តទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ សហវ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ស្តីពីការអនុវត្តបទបញ្ញត្តទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ....ចុះថ្ងៃទី ......ខែ.......ឆ្នាំ ១៩៩៦ ស្តីពីការប្រព្រឹត្តទៅនៃរដ្ឋនេយ្យបុរេប្រទាន
- បានឃើញតំរូវការចាំបាច់ នៃការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុបច្ចុប្បន្ន

សំរេច

ប្រការ ១ : ត្រូវបានតែងតាំងលោក **ឈិន កុសល** ប្រធានការិយាល័យគណនេយ្យ តួនាទី ....អោយទទួលការងារបច្ចុប្បន្នជា រដ្ឋនេយ្យករបុរេប្រទាន

នៅអមក្រសួងយុត្តិធម៌ និងលោក ស្រី **លី ចាន់ថុត** អោយទទួលការងារជំនួស ។

ប្រការ ២ : ការតែងតាំងនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ខែ ឆ្នាំ ១៩៩៦ នេះតទៅ ។

ប្រការ ៣ : ខុទ្ទកាល័យ មន្ទីរ រតនាគារជាតិ នាយកដ្ឋាន ព្រមទាំងអង្គភាពទាំងអស់ក្រោមឱវាទក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងយុត្តិធម៌ ព្រមទាំងលោក **ឈិត កុសល** និងលោក ស្រី **លី ចាន់ថុត** មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងក្រសួងយុត្តិធម៌	ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
រដ្ឋលេខាធិការ	ហត្ថលេខានិងត្រា
ហត្ថលេខានិងត្រា	**គាត ឈន់**
អ៊ុក វិធុន	

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសអន្តរក្រសួងលេខ ៤៨៨ សហវ.មប្រក.

ស្តីពីការបង្កើតរដ្ឋលេខាធិការប្រចាំការ

នៅក្រសួងយុត្តិធម៌

* * *

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស.៩៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ន ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ អនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ សហវ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ អនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០០៣ សហវ.ម ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការ ប្រព្រឹត្តិទៅនៃរជ្ជទេយ្យបុរេប្រទាន
- បានឃើញតំរូវការចាំបាច់ នៃការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុបច្ចុប្បន្ន

សំរេច

ប្រការ ១ : ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទាននៅក្រសួងយុត្តិធម៌ ដើម្បីទូទាត់ចំណាយទាំងឡាយ ដែលមានចែង ក្នុងមាត្រា ៦៤ នៃអនុក្រឹត្យលេខ ៨២ អនក្របក. ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ ។

ចំនួនទឹកប្រាក់ជាអតិបរមានៃចំណាយដែលអនុញ្ញាតអោយរជ្ជទេយ្យករបុរេប្រទានធ្វើការទូទាត់ក្រោមកំណត់គិត ៥០០.០០០ តាមចំណាត់ថ្នាក់ចំណាយនីមួយៗដូចបានចែងនៅក្នុងឧបសម្ព័ន្ធ ត្រូវកំណត់ដោយទេសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ ។

ប្រការ ២ : ចំនួនទឹកប្រាក់នៃរជ្ជទេយ្យបុរេប្រទានត្រូវបានកំណត់ត្រឹមចំនួន ១៣.០០០.០០០រៀល ។

ប្រការ ៣ : ខុទ្ទកាល័យ មន្ទីរ រតនាគារជាតិ នាយកដ្ឋាន ព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ ក្រោមឱវាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងយុត្តិធម៌ មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងក្រសួងយុត្តិធម៌
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
អ៊ុក វិធូន

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ហត្ថលេខានិងត្រា
គាត ឈន់

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសអន្តរក្រសួងលេខ ៤៨៩ សហវ.មប្រក
ស្តីពីការបង្កើតនិងតែងតាំងភ្នាក់ងារបើកផ្តល់
សំរាប់បើកបៀវត្សជូនមន្ត្រីរាជការ

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស.រកតប ១០៩៤.៩៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

- បានឃើញច្បាប់ពីហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ ន.ស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.កប ចុះថ្ងៃទី ១៦ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៥ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន

សំរេច

ប្រការ ១ : ប្រាក់បៀវត្សមន្ត្រីរាជការនៃក្រសួងយុត្តិធម៌នឹងត្រូវបើកផ្តល់តាមរយៈរដ្ឋនេយ្យករ ដែលមានឈ្មោះថា « ភ្នាក់ងារបើកផ្តល់ » ។

ប្រការ ២ : លោក **សៅ សារឿន** ត្រូវបានតែងតាំងជាភ្នាក់ងារបើកផ្តល់នៅក្រសួងយុត្តិធម៌ នឹងលោក **ស៊ុំ ពិសេដ្ឋ** ត្រូវបានតែងតាំងជាភ្នាក់ងារបើកផ្តល់ជំនួស ។

ប្រការ ៣ : លោក **សៅ សារឿន** ត្រូវបានអនុវត្តអោយបើកគណនីប្រាក់នៅរតនាគារជាតិ ដើម្បីទទួលមូលនិធិសំរាប់យកទៅបើកបៀវត្សជូនមន្ត្រីរាជការ ។

ប្រការ ៤ : បែបបទនៃការអនុវត្តន៍ បើកផ្តល់បៀវត្ស នឹងត្រូវកំណត់ដោយ សេចក្តីណែនាំជាក្រោយ ។

ប្រការ ៥ : ភ្នាក់ងារបើកផ្តល់ត្រូវទទួលខុសត្រូវផ្តល់ចំពោះប្រាក់កាស និង មូលនិធិដែលបានទទួលដើម្បីយកទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការ ។

ប្រការ ៦ : សេចក្តីសំរេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

ប្រការ ៧ : ខុទ្ទកាល័យ មន្ទីរ នាយកដ្ឋានថវិកា នាយករដ្ឋានហិរញ្ញវត្ថុ រតនាគារជាតិព្រមទាំងនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទាំងអស់នឹង

ក្រសួងយុត្តិធម៌ព្រមទាំង លោក **សៅ សារឿន** ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
អ៊ុក វិធុន

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ហត្ថលេខានិងត្រា
គាត ឈន់

* * *

២– ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ក្រសួងបរិស្ថាន

រាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៦

ប្រកាសអន្តរក្រសួង លេខ ៥០៥ សហវ.មប្រក
ស្តីពីការតែងតាំងជំនួយការប្រចាំទីស្ដីការ
នៅក្រសួងបរិស្ថាន

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
រដ្ឋមន្ត្រីក្រសួង បរិស្ថាន

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
